ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.១៨.០៤.៨...០៧៧០ [illegible]

ថ្ងៃ ចន្ទ ១១កើត ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរ (Bakong Tourists App) ជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ Mastercard

នាថ្ងៃចន្ទ ១១កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរ (Bakong Tourists App) ជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ Mastercard នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ។ ពិធីនេះមានការអញ្ជើញចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងទេសចរណ៍ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូ-ហិរញ្ញវត្ថុកម្ពុជា សមាគមសហព័ន្ធហិរញ្ញវត្ថុនិងបច្ចេកវិទ្យានៃកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិសរុបប្រមាណ ៣៥០រូប។

ការដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរ ជាមួយក្រុមហ៊ុន Mastercard នេះ មានគោលបំណងពង្រីកវិសាលភាព និងជំរុញការប្រើប្រាស់កម្មវិធីទូទាត់បាគងទេសចរ ដើម្បីសម្រួលប្រតិបត្តិការទូទាត់របស់ភ្ញៀវទេសចរអន្តរជាតិដែលធ្វើដំណើរមកប្រទេសកម្ពុជា។

តាមរយៈកិច្ចសហប្រតិបត្តិការនេះ ភ្ញៀវទេសចរអន្តរជាតិនឹងទទួលបានបទពិសោធន៍ទូទាត់ថ្លៃទំនិញនិងសេវាតាមប្រព័ន្ធឌីជីថលកាន់តែងាយស្រួល ដោយគ្រាន់តែទាញយកកម្មវិធីទូទាត់បាគងទេសចររួចបញ្ចូលទឹកប្រាក់ក្នុងគណនីបាគងដោយភ្ជាប់ជាមួយប័ណ្ណទូទាត់ Mastercard ដែលមានស្រាប់ពីប្រទេសដើមរបស់ខ្លួន។ ទន្ទឹមនេះ អាជីវកម្មក្នុងស្រុកអាចផ្តល់បទពិសោធន៍នៃការទូទាត់តាមប្រព័ន្ធឌីជីថលប្រកបដោយភាពងាយស្រួល រហ័ស និងសុវត្ថិភាព ដល់ភ្ញៀវទេសចរដែលធ្វើដំណើរមកកម្ពុជាផងដែរ។

សមិទ្ធផលថ្មីនេះសំដៅរួមចំណែកជំរុញវិស័យទេសចរណ៍នៅកម្ពុជា និងលើកកម្ពស់ការធ្វើបរិវត្តកម្មឌីជីថល តាមរយៈការពង្រីកលទ្ធភាពក្នុងការទូទាត់ឌីជីថលឱ្យកាន់តែសម្បូរបែប ងាយស្រួល ប្រសិទ្ធភាព និងសុវត្ថិភាព។

លោក Sapan Shah អនុប្រធានជាន់ខ្ពស់ទទួលបន្ទុកផ្នែកដំណោះស្រាយសម្រាប់ការទទួលយកប័ណ្ណរបស់ក្រុមហ៊ុន Mastercard បានលើកឡើងថា៖ "Mastercard មានសេចក្តីរំភើបរីករាយដែលបានសហការជាមួយធនាគារជាតិនៃកម្ពុជា តាមរយៈការតភ្ជាប់ជាមួយប្រព័ន្ធបាគង ដើម្បីធ្វើឱ្យប្រតិបត្តិការទូទាត់តាមឌីជីថលកាន់តែងាយស្រួលសម្រាប់ទាំងភ្ញៀវទេសចរ និងអាជីវករក្នុងស្រុកនៅកម្ពុជា។

លើសពីនេះ យើងក៏កំពុងជួយជំរុញអាជីវករក្នុងស្រុកឱ្យទទួលយកការទូទាត់ដោយគ្មានសាច់ប្រាក់ ដោយបង្កើនប្រសិទ្ធភាព និងកាត់បន្ថយបញ្ហាប្រឈមនានាទាក់ទងនឹងការគ្រប់គ្រងសាច់ប្រាក់។ នេះគឺជាការបោះជំហានដ៏សំខាន់មួយរបស់កម្ពុជាក្នុងការធ្វើបរិវត្តកម្មសេដ្ឋកិច្ចឌីជីថល។ ក្រោមកិច្ចសហប្រតិបត្តិការនេះ អតិថិជនរបស់ Mastercard ទាំងអស់អាចបញ្ចូលទឹកប្រាក់ទៅក្នុងគណនីបាគងដោយផ្ទាល់ តាមរយៈកម្មវិធីទូទាត់បាគងសម្រាប់ទេសចរដែលទើបតែត្រូវបានដាក់ឱ្យដំណើរការកាលពីពេលថ្មីៗនេះ។ ភ្ញៀវទេសចរ នឹងរីករាយជាមួយបទពិសោធថ្មីនេះក្នុងអំឡុងពេលធ្វើដំណើរកម្សាន្តនៅក្នុងប្រទេសកម្ពុជា។"

លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានមានប្រសាសន៍ថា ៖ "កិច្ចសហប្រតិបត្តិការនេះ មិនត្រឹមតែពង្រីកមុខងាររបស់កម្មវិធីទូទាត់បាគងសម្រាប់ទេសចរប៉ុណ្ណោះទេ ថែមទាំងសបញ្ជាក់ពីចក្ខុវិស័យរួមរបស់ធនាគារជាតិនៃកម្ពុជាក្នុងការរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចតាមរយៈវិស័យទេសចរណ៍ផងដែរ។ ភ្ញៀវទេសចរអន្តរជាតិនឹងទទួលបានបទពិសោធន៍ក្នុងការទូទាត់យ៉ាងរលូន និងឆាប់រហ័ស ដែលបានរួមចំណែកដល់និរន្តរភាព និងភាពធន់នៃវិស័យទេសចរណ៍របស់យើង។ លើសពីនេះ គំនិតផ្តួចផ្តើមនេះក៏ស្របតាមគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។"៕

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA